# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ នៅក្រសួងមហាផ្ទៃ




**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានបញ្ជាចំៗឲ្យអាជ្ញាធររាជធានីភ្នំពេញ បំបែកសំបុកគ្រឿងញៀននៅត្រពាំងឈូក ឲ្យខាងតែបាន។ នេះបើតាមការបង្ហោះឲ្យដឹងនៅលើ Facebook ផ្លូវការរបស់ ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ។

**សម្តេចក្រឡាហោម ស ខេង** ថ្លែងបញ្ជាខ្លាំងៗបែបនេះ ខណៈសម្តេចចូលរួមនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃយុទ្ធនាការបង្ក្រាប គ្រឿងញៀន លើកទី១ ប្រចាំខែមករា ឆ្នាំ២០១៧ និងផ្សព្វផ្សាយសេចក្តីសម្រេចរាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការចម្រុះ ប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧។

នៅលើបណ្តាញសង្គម Facebook ឯកឧត្តម ខៀវ កាញារីទ្ធ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ បានបញ្ជាក់យ៉ាងដូច្នេះថា **«សម្តេច សខេង សុំអោយអាជ្ញាធររាជធានីភ្នំពេញ បំបែកសំបុកគ្រឿងញៀន នៅត្រពាំងឈូក អោយខាងតែបាន»**។

គួរបញ្ជាក់ថា យោងតាមរបាយការណ៍កិច្ចប្រជុំបូកសរុបលទ្ធផលនៃយុទ្ធនាការបង្រ្កាប គ្រឿងញៀន លើកទី១ ប្រចាំខែមករា ឆ្នាំ២០១៧ និងផ្សព្វផ្សាយ សេចក្តីសម្រេច រាជរដ្ឋាភិបាលស្តីពីការបង្កើត គណៈកម្មការចម្រុះ ប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបង្ហាញឲ្យដឹងថា នៅក្នុងខែមករា ឆ្នាំ២០១៧ យុទ្ធនាការប្រយុទ្ធប្រឆាំង គ្រឿងញៀនខុសច្បាប់លើកទី១ នៅកម្ពុជាកម្លាំងសមត្ថកិច្ច បានបង្រ្កាបបាន ចំនួន១,១៤៤ករណី ឃាត់ខ្លួនជនសង្ស័យដែលជាអ្នកជួញដូរ និងប្រើប្រាស់ចំនួន ២៧៧៣នាក់។







